# វិវរណៈ និង ទីបន្ទាល់ផ្ទាល់ខ្លួន

*ដោយ បាបារ៉ា ថមសុន*
*ទីប្រឹក្សាទីពីរ នៅក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅ*

ជាច្រើនឆ្នាំកន្លងទៅ ពេលខ្ញុំនៅជានិសិត្សមហាវិទ្យាល័យ ខ្ញុំបានស្ដាប់សន្និសីទទូទៅតាមវិទ្យុ ពីព្រោះយើងគ្មានទូរទស្សន៍ក្នុងផ្ទះល្វែងតូចរបស់យើងនោះឡើយ ។ អ្នកនិយាយទាំងឡាយក្នុងសន្និសីទអស្ចារ្យណាស់ ហើយខ្ញុំពេញចិត្តនឹងអារម្មណ៍ព្រះវិញ្ញាណដ៏ខ្លាំងមកពីព្រះវិញ្ញាណបរិសុទ្ធ ។

ខ្ញុំចាំយ៉ាងច្បាស់នៅពេលអ្នកមានសិទ្ធិអំណាចទូទៅមួយរូប បានមានប្រសាសន៍អំពីព្រះអង្គសង្គ្រោះ និងការបម្រើរបស់ទ្រង់ រួចហើយបានថ្លែងទីបន្ទាល់ដ៏ក្លៀវក្លា ។ ព្រះវិញ្ញាណបរិសុទ្ធបានថ្លែងទីបន្ទាល់ដល់ព្រលឹងខ្ញុំថា គាត់បាននិយាយអំពីសេចក្ដីពិត ។ នៅគ្រានោះ ខ្ញុំបានដឹងយ៉ាងច្បាស់ថា ព្រះអង្គសង្គ្រោះមានព្រះជន្មរស់ ។ ខ្ញុំក៏បានដឹងយ៉ាងច្បាស់ផងដែរថា ខ្ញុំកំពុងតែទទួលបទពិសោធន៍វិវរណៈផ្ទាល់ខ្លួន ដែលបញ្ជាក់មកកាន់ខ្ញុំថា « ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រារបស់ព្រះ » នោះដែរ  ។ [1]

ពេលមានអាយុប្រាំបីឆ្នាំ ខ្ញុំបានទទួលបុណ្យជ្រមុជទឹក ហើយបានទទួលពិធីបញ្ជាក់ និងបានទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ វាគឺជាពរជ័យមួយដ៏អស្ចារ្យ ប៉ុន្តែក្រោយមកវាកាន់តែសំខាន់ នៅពេលខ្ញុំធំឡើង ហើយទទួលបានបទពិសោធន៍ពីអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ តាមរបៀបជាច្រើនចាប់តាំងពីពេលនោះមក ។

ជាញឹកញាប់ នៅពេលយើងធំដឹងក្ដីពីកុមារភាពមកយុវវ័យ បន្ទាប់មកដល់មជ្ឈឹមវ័យ នោះយើងមានឧបសគ្គ និងបទពិសោធន៍តាមផ្លូវ ដែលបណ្ដាលឲ្យយើងដឹងថា យើងត្រូវការជំនួយពីព្រះតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ នៅពេលកើតមានបញ្ហា យើងអាចសួរខ្លួនឯងថា « តើមានអ្វីអាចឆ្លើយចំពោះបញ្ហារបស់ខ្ញុំបាន ? » ហើយ « តើខ្ញុំអាចដឹងថា ខ្ញុំត្រូវធ្វើអ្វីដោយរបៀបណាទៅ ? »

ជាញឹកញាប់ ខ្ញុំចាំដំណើររឿងនៅក្នុងព្រះគម្ពីរមរមន អំពីលីហៃបង្រៀនដំណឹងល្អដល់គ្រួសាររបស់គាត់ ។ គាត់បានចែកចាយវិវរណៈ និងការបង្រៀនអំពីរឿងដែលនឹងកើតមាននៅថ្ងៃចុងក្រោយយ៉ាងច្រើនជាមួយពួកគេ ។ នីហ្វៃបានស្វែងរកការណែនាំពីព្រះអម្ចាស់ ដើម្បីឲ្យបានយល់ដឹងពេញលេញអំពីការបង្រៀនរបស់ឪពុកគាត់ ។ គាត់ត្រូវបានលើកតម្កើង ប្រទានពរ និងបំផុសគំនិត ដើម្បីដឹងថា ការបង្រៀនរបស់ឪពុកគាត់ពិត ។ រឿងនោះធ្វើឲ្យនីហ្វៃអាចធ្វើតាមព្រះបញ្ញត្តិនៃព្រះអម្ចាស់ដោយយកចិត្តទុកដាក់ ហើយរស់នៅក្នុងជីវិតសុចរិត ។ គាត់បានទទួលវិវរណៈផ្ទាល់ខ្លួនដើម្បីដឹកនាំគាត់ ។

ផ្ទុយទៅវិញ បងប្អូនប្រុសរបស់គាត់ ត្រូវបានឈ្លោះប្រកែកនឹងគ្នាដោយសារពួកគេពុំយល់ការបង្រៀនរបស់ឪពុករបស់ខ្លួន ។ នីហ្វៃបានសួរសំណួរដ៏សំខាន់មួយថា ៖ « តើពួកបងៗបានសុំដល់ព្រះអម្ចាស់ហើយឬនៅ ? » [2]

ពួកគេបានឆ្លើយទាំងភាពទន់ខ្សោយថា ៖ « យើងមិនទាន់បានសូមទេ ត្បិតព្រះអម្ចាស់ ទ្រង់មិនបានធ្វើឲ្យយើងដឹងរឿងបែបនេះទេ » ។ [3] នីហ្វៃឆ្លៀតឱកាសនេះ បង្រៀនដល់បងៗគាត់ អំពីរបៀបដើម្បីទទួលវិវរណៈផ្ទាល់ខ្លួន ។ គាត់មានប្រសាសន៍ថា ៖ « តើបងៗមិនចាំរឿងទាំងឡាយ ដែលព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលទេឬ ? បើសិនជាអ្នកណាមិនធ្វើចិត្តរឹងរូស ហើយសូមដល់យើង ដោយសេចក្ដីជំនឿ ដោយជឿថា អ្នកនឹងបានទទួលដោយមានចិត្តឧស្សាហ៍កាន់តាមបញ្ញត្តិទាំងឡាយរបស់យើង នោះរឿងទាំងនេះ នឹងត្រូវបានធ្វើឲ្យអ្នកដឹងជាប្រាកដ » ។ [4]

របៀបដើម្បីទទួលបានវិវរណៈផ្ទាល់ខ្លួន គឺច្បាស់លាស់ណាស់ ។ យើងចាំបាច់ត្រូវមានបំណងប្រាថ្នាចង់ទទួលបានវិវរណៈ យើងមិនត្រូវមានចិត្តរឹងរូសឡើយ រួចហើយយើងចាំបាច់ត្រូវសូមដោយជំនឿ ជឿដោយពិតថា យើងនឹងទទួលចម្លើយ បន្ទាប់មកមានចិត្តឧស្សាហ៍កាន់តាមព្រះបញ្ញត្តិរបស់ព្រះ ។

ការធ្វើតាមគំរូនេះ ពុំមានន័យថា រាល់ពេលយើងទូលសួរសំណួរណាមួយទៅព្រះអម្ចាស់ នោះចម្លើយនឹងមកដល់ភ្លាមជាមួយនឹងការប្រាប់យ៉ាងលំអិតអំពីអ្វីដែលត្រូវធ្វើនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ វាមានន័យថា បើយើងឧស្សាហ៍កាន់តាមព្រះបញ្ញត្តិ ហើយសុំដោយសេចក្ដីជំនឿ នោះចម្លើយនឹងមកដល់តាមរបៀបរបស់ព្រះអម្ចាស់ និង តាមពេលរបស់ទ្រង់ ។

កាលពីក្មេង ខ្ញុំបានគិតថា វិវរណៈផ្ទាល់ខ្លួន ឬចម្លើយចំពោះការអធិស្ឋាន នឹងមានជាសម្លេងដែលអាចស្ដាប់ឮបាន ។ តាមពិត វិវរណៈមួយចំនួនមានមកតាមរយៈការស្ដាប់សម្លេងពិតមួយ ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំបានដឹងថា ព្រះវិញ្ញាណមានបន្ទូលតាមរបៀបជាច្រើន ។ គោលលទ្ធិ និង សេចក្ដី

សញ្ញា កណ្ឌទី6 បានពន្យល់ពីរបៀបជាច្រើនដែលយើងអាចទទួលវិវរណៈ ៖ « ហើយមើលចុះ ដរាបណា អ្នកសូមជាញឹកញាប់ នោះ អ្នកបានទទួលការបង្គាប់ពីព្រះវិញ្ញាណរបស់យើង» ។ [5] « យើងបានបំភ្លឺគំនិតរបស់អ្នក » ។ [6] « តើយើងពុំបាននិយាយដោយភាពសុខសាន្តដល់គំនិតរបស់អ្នកអំពីការណ៍នោះទេឬអី? » [7]

នៅក្នុងបទគម្ពីរមួយទៀត យើងរៀនបន្ថែមអំពីការទទួលវិវរណៈ ៖ « យើងនឹងប្រាប់អ្នកនៅក្នុងគំនិតរបស់អ្នក និងនៅក្នុងចិត្តរបស់អ្នក ដោយព្រះវិញ្ញាណបរិសុទ្ធដែលនឹងសណ្ឋិតមកលើអ្នក ហើយដែលនឹងគង់នៅក្នុងចិត្តរបស់អ្នក ។ ឥឡូវនេះ មើលចុះនេះជាវិញ្ញាណនៃវិវរណៈ » ។ [8]

« យើងនឹងបណ្តាលឲ្យទ្រូងរបស់អ្នកខ្វួលខ្វាញ់ខាងក្នុង ហេតុដូច្នោះហើយ អ្នកនឹងមានអារម្មណ៍ថា ការណ៍នោះត្រឹមត្រូវ » ។ [9] « យើងនឹងរំលែកដល់អ្នកនូវព្រះវិញ្ញាណរបស់យើង ដែលនឹងបំភ្លឺគំនិតរបស់អ្នក ដែលនឹងបំពេញព្រលឹងរបស់អ្នកដោយសេចក្តីអំណរ » ។ [10]

ជាញឹកញាប់ណាស់ ដែលវិវរណៈផ្ទាល់ខ្លួននឹងកើតមាន នៅពេលយើងសិក្សាព្រះគម្ពីរ ស្តាប់ និងធ្វើតាមដំបូន្មានរបស់ព្យាការី និងអ្នកដឹកនាំសាសនាចក្រដទៃទៀត ហើយព្យាយាមរស់នៅដោយស្មោះត្រង់ ហើយ សុចរិត ។ ពេលខ្លះការបំផុសគំនិតនឹងកើតមានចេញមកពីខគម្ពីរតែមួយ ឬ មកពីសុន្ទរកថាក្នុងសន្និសីទមួយបន្ទាត់ ។ ប្រហែលជាចម្លើយរបស់អ្នកនឹងមក នៅពេលកុមារថ្នាក់បឋមសិក្សាច្រៀងចម្រៀងដ៏ពិរោះ ។ ទាំងនេះគឺជាទម្រង់នៃវិវរណៈទាំងអស់ ។

ក្នុងគ្រានៃការស្តារឡើងវិញជំនាន់មុន មានសមាជិកជាច្រើនព្យាយាមស្វែងរកវិវរណៈដោយឧស្សាហ៍ ហើយត្រូវបានប្រទានពរ និងបំផុសគំនិតឲ្យដឹងនូវអ្វីដែលត្រូវធ្វើ ។

បងស្រី អេលីហ្សា អ័រ ស្ន ត្រូវបានព្យាការី ព្រិកហាំ យ៉ង់ ហៅឲ្យជួយលើកទឹកចិត្ត និងបង្រៀនដល់បងប្អូនស្រីនៃសាសនាចក្រ ។ គាត់បានបង្រៀនថា ស្ត្រីម្នាក់ៗ អាចទទួលការបំផុសគំនិត ដើម្បីដឹកនាំពួកគេនៅក្នុងជីវិតរស់នៅផ្ទាល់ខ្លួន ក្នុងគ្រួសារ និងក្នុងការទទួលខុសត្រូវនៅក្នុងសាសនាចក្ររបស់ពួកគេ ។ គាត់មានប្រសាសន៍ថា ៖ « ចូរប្រាប់បងប្អូនស្ត្រី ឲ្យឆ្ពោះទៅមុខ ហើយបំពេញកាតព្វកិច្ចរបស់ពួកគេ ដោយរាបសា ហើយស្មោះត្រង់ រួចហើយព្រះវិញ្ញាណនៃព្រះនឹងមានមកលើពួកគេ ហើយពួកគេនឹងបានទទួលពរនៅក្នុងកិច្ចការរបស់ពួកគេ ។ ចូរឲ្យពួកគេស្វែងរកប្រាជ្ញាជាជាងអំណាច នោះពួកគេនឹងមានអំណាចទាំងអស់ នៅពេលពួកគេយកប្រាជ្ញាមកប្រើប្រាស់ » ។ [11]

បងស្រី ស្ន បានបង្រៀនស្ត្រីឲ្យស្វែងរកការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ។ គាត់មានប្រសាសន៍ថា ព្រះវិញ្ញាណបរិសុទ្ធ « នឹងធ្វើឲ្យស្កប់ស្កល់ចិត្ត ហើយបំពេញបំណង ប្រាថ្នានៅក្នុងដួងចិត្តមនុស្សជាតិ ហើយបំពេញនូវភាពខ្វះចន្លោះទាំងអស់ ។ នៅពេលខ្ញុំពោរពេញដោយព្រះវិញ្ញាណ នោះព្រលឹងរបស់ខ្ញុំស្កប់ស្កល់ » ។ [12] ប្រធាន អុជដូហ្វបានបង្រៀនថា « វិវរណៈ និង ទីបន្ទាល់ ពុំកើតមានដោយកម្លាំងលើសលុបជានិច្ចនោះទេ ។ ចំពោះមនុស្សជាច្រើន ទីបន្ទាល់កើតមានយឺតៗ --- ម្តងបន្តិចៗ » ។ គាត់មានប្រសាសន៍បន្ថែមទៀតថា ៖ « ចូរយើងស្វែងរកពន្លឺនៃការបំផុសគំនិតផ្ទាល់ខ្លួនដោយអស់ពីចិត្ត ។ ចូរយើងទូលសុំដល់ព្រះអម្ចាស់ ដើម្បីប្រទានពរដល់គំនិត និងព្រលឹងរបស់យើងជាមួយផ្កាភ្លើងនៃសេចក្តីជំនឿ ដែលនឹងជួយឲ្យយើងអាចទទួលបាន និងស្គាល់ការបម្រើដ៏ទេវភាពនៃព្រះវិញ្ញាណបរិសុទ្ធ » ។ [13]

ទីបន្ទាល់របស់យើង ការពារ និងពង្រឹងយើង នៅពេលយើងប្រឈមមុខនឹងឧបសគ្គក្នុងជីវិតរស់នៅប្រចាំថ្ងៃ ។ មនុស្សមួយចំនួនពុះពារដោយលំបាកនឹងបញ្ហាសុខភាព មនុស្សខ្លះទៀតជួបនឹងបញ្ហាហិរញ្ញវត្ថុអ្នកដទៃទៀត មានបញ្ហាក្នុងអាពាហ៍ពិពាហ៍ ឬកូនចៅរបស់ពួកគេ ។ មនុស្សមួយចំនួនរងទុក្ខដោយភាពឯកោ ឬការសង្ឃឹម និងក្តីស្រមៃមិនសមតាមបំណង ។ ទីបន្ទាល់របស់យើង ផ្គុំជាមួយនឹងសេចក្តីជំនឿរបស់យើងទៅលើព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ និងចំណេះដឹងរបស់យើង អំពីផែនការនៃសេចក្តីសង្គ្រោះ ជួយយើងឲ្យឆ្លងកាត់គ្រានៃការសាកល្បង និងទុក្ខលំបាកទាំងនេះ ។

ក្នុងសៀវភៅ *Daughters in My Kingdom* (*បុត្រីនៅក្នុងនគររបស់យើង*) យើងអានអំពីបងស្រី ហេដវីគ បៀរីដេល ជាស្ត្រីនៅប្រទេសអាល្លឺម៉ង់ ដែលរងទុក្ខសោកសៅយ៉ាងច្រើន និងគ្មានទីជម្រក អំឡុងពេលសង្គ្រាមលោកលើកទីពីរ ។ ដោយសារសេចក្តីស្រឡាញ់ និងចិត្តសប្បុរសពីកំណើត ទោះជាគាត់មានតម្រូវការយ៉ាងខ្លាំងក្តី ក៏គាត់មានឆន្ទៈចង់ចែកចាយអាហាររបស់គាត់ជាមួយនឹងឈ្លើយសង្គ្រាមដែលស្រេកឃ្លានដែរ ។ ក្រោយមក គេសួរគាត់ថា តើគាត់អាច « រក្សាទីបន្ទាល់អំឡុងពេលមានឧបសគ្គទាំងនេះ » ដោយរបៀបណា នោះគាត់បានឆ្លើយថា « ខ្ញុំពុំបានរក្សាទីបន្ទាល់គ្រប់គ្រាទាំងនោះទេ --- ប៉ុន្តែទីបន្ទាល់រក្សាខ្ញុំវិញទេតើ » ។ [14]

ដោយសារយើងមានទីបន្ទាល់រឹងមាំ នោះពុំមានន័យថា វានឹងនៅដដែលជានិច្ចនោះទេ ។ (យើងត្រូវតែចិញ្ចឹមបីបាច់ ហើយពង្រឹងទីបន្ទាល់ ដើម្បីឲ្យវានឹងមានអំណាចគ្រប់គ្រាន់ ដើម្បីទ្រទ្រង់យើង ) ។ មានមូលហេតុមួយដែលយើង « ជួបជុំគ្នាជាញឹកញាប់ » ដើម្បីយើងអាចទទួលទានសាក្រាម៉ង់ រំឭក

សេចក្ដីសញ្ញារបស់យើង និង « ចញ្ចឹមបីបាច់ដោយព្រះបន្ទូលដ៏ល្អនៃព្រះ » ។ គឺជាព្រះបន្ទូលដ៏ល្អនៃព្រះ ដែលរក្សាយើង « ឲ្យចាំយាមក្នុងការអធិស្ឋានជានិច្ច ដោយពឹងផ្អែកទៅលើតែព្រះគុណនៃព្រះគ្រីស្ទដែលជាមេផ្ដើម ហើយជាមេសម្រេចនូវសេចក្ដីជំនឿរបស់[ យើង ] » ។

អែលឌើរ ដេវីឌ អេ បែដណា បានបង្រៀនយើងថា « នៅពេលយើងស្វែងរកដោយត្រឹមត្រូវ ហើយទូលសុំវិវរណៈមកពីព្រះវិញ្ញាណបរិសុទ្ធ នោះខ្ញុំសន្យានឹងអ្នកថា អ្នកនឹង ‹ ដើរក្នុងពន្លឺនៃព្រះអម្ចាស់ › ( អេសាយ 2:5 នីហ្វៃទី2 12:5 ) ។ ពេលខ្លះវិញ្ញាណនៃវិវរណៈនឹងមានភ្លាម ហើយ ខ្លាំងក្លា ពេលខ្លះដោយប្រសប់ និងបន្តិចម្ដងៗ ហើយញឹកញាប់ណាស់ដែលយើងមិនបានទទួលស្គាល់ដោយសារតែទន់ភ្លន់ពេក ។ ប៉ុន្ដែមិនថាតាមគំរូណាដែលពរជ័យនេះត្រូវបានទទួលនោះទេ ពន្លឺដែលវិវរណៈផ្ដល់ឲ្យនឹងចែងចាំង ហើយពង្រីកដល់ព្រលឹងរបស់អ្នក បំភ្លឺការយល់ដឹងរបស់អ្នក ( សូមមើលអាលម៉ា 5:7, 32:28) ហើយដឹកនាំ និងការពារអ្នក និងគ្រួសាររបស់អ្នក » ។ [16]

ព្រះអម្ចាស់មានព្រះទ័យចង់ប្រទានពរដល់យើងនូវការណែនាំ ប្រាជ្ញា និងការដឹកនាំក្នុងជីវិតរស់នៅយើង ។ ទ្រង់មានព្រះទ័យចង់ចាក់ស្រោចព្រះវិញ្ញាណរបស់ទ្រង់មកលើយើង ។ ជាថ្មីម្ដងទៀត សម្រាប់វិវរណៈផ្ទាល់ខ្លួន យើងចាំបាច់ត្រូវមានបំណងប្រាថ្នាដើម្បីទទួលយក យើងមិនត្រូវមានចិត្តរឹងរូសទេ បន្ទាប់មកយើងចាំបាច់ត្រូវសុំដោយជំនឿ ជឿដោយពិតថា យើងនឹងទទួលចម្លើយ បន្ទាប់មកមានចិត្តឧស្សាហ៍កាន់តាមបញ្ញត្តិរបស់ព្រះ ។ រួចហើយនៅពេលយើងស្វែងរកចម្លើយចំពោះសំណួររបស់យើង នោះទ្រង់នឹងប្រទានពរយើងនូវព្រះវិញ្ញាណរបស់ទ្រង់ ។ ខ្ញុំធ្វើបន្ទាល់ពីការនេះ ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. គោលលទ្ធិ និង សេចក្ដីសញ្ញា 46:13 ។
2. នីហ្វៃទី 1 15:8 ។
3. នីហ្វៃទី 1 15:8។
4. នីហ្វៃទី1 15:11 សូមមើល ខ 10 ផងដែរ ។
5. គោលលទ្ធិ និង សេចក្ដីសញ្ញា 6:14 ។
6. គោលលទ្ធិ និង សេចក្ដីសញ្ញា 6:15 ។
7. គោលលទ្ធិ និង សេចក្ដីសញ្ញា 6:23 ។
8. គោលលទ្ធិ និង សេចក្ដីសញ្ញា 8:2--3 ។
9. គោលលទ្ធិ និង សេចក្ដីសញ្ញា 9:8 ។
10. គោលលទ្ធិ និង សេចក្ដីសញ្ញា 11:13 ។
11. *Daughters in My Kingdom: The History and Work of Relief Society* (ឆ្នាំ 2011) ទំព័រ 45 ។
12. *Daughters in My Kingdom* ទំព័រ 46។
13. Dieter F. Uchtdorf, «Your Potential, Your Privilege » *Liahona* និង *Ensign* ខែ ឧសភា ឆ្នាំ 2011 ទំព័រ 60 ។
14. សូមមើល *Daughters in My Kingdom* ទំព័រ 79 ។
15. មរ៉ូណៃ 6:4--6 ។
16. David A. Bednar «The Spirit of Revelation» *Liahona* និង *Ensign* ខែ ឧសភា ឆ្នាំ 2011 ទំព័រ 90 ។